00852376

E238

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 08 / 10 / 2012
ម៉ោង (Time/Heure): 15:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH Arun

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អនុស្សរណៈ-អង្គជំនុំជម្រះសាលាដំបូង** **សាធារណៈ / Public**

ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២

**ជូនចំពោះ:** **មេធាវីការពារជនជាប់ចោទ អៀង សារី; សហព្រះរាជអាជ្ញា; សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **ការតែងតាំងសាស្ត្រាចារ្យ A. John CAMPBELL សម្រាប់ជនជាប់ចោទ អៀង សារី**

១. បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈរបស់ខ្លួន (ឯកសារ E233) រួចមក អង្គជំនុំជម្រះសាលាដំបូងបានផ្ញើទៅអ្នកជំនាញ សាស្ត្រាចារ្យ A. John CAMPBELL នូវរាល់ព័ត៌មានវេជ្ជសាស្ត្រទាំងអស់ ដែលមានចាប់តាំងពីពេលដែលជនជាប់ចោទរូបនេះត្រូវបាន បញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ចាប់តាំងពីថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១២ បន្ថែមពីលើប្រតិចារឹកចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ដែលគ្រូពេទ្យព្យាបាលនៃមន្ទីរពេទ្យខាងលើបានមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។

២. លោកសាស្ត្រាចារ្យ Campbell បានគូសបញ្ជាក់ប្រាប់អង្គជំនុំជម្រះសាលាដំបូងថា តាមរយៈព័ត៌មានវេជ្ជសាស្ត្រដែលគាត់បានទទួល គាត់ពិបាកជឿជាក់អំពីមូលហេតុនៃការប្រែប្រួលលើការធ្វើរោគវិនិច្ឆ័យរបស់ជនជាប់ចោទ អៀង សារី ចាប់តាំងពីពេលគាត់បាន

ពិនិត្យជនជាប់- ចោទជាលើកចុងក្រោយរួចមក។ អង្គជំនុំជម្រះយល់ឃើញថាជាការសមស្របដើម្បីចាត់តាំងឱ្យសាស្ត្រាចារ្យ Campbell ត្រឡប់មកកម្ពុជាវិញ និងចាត់តាំងវេជ្ជបណ្ឌិតកម្ពុជាមួយរូប ដែលមានជំនាញវេជ្ជសាស្ត្រសមស្របដើម្បី៖

ក) ពិនិត្យជនជាប់ចោទ អៀង សារី និងពិនិត្យមើលឡើងវិញរាល់ព័ត៌មានវេជ្ជសាស្ត្រថ្មីៗ និងតេស្តដែលបានធ្វើលើជនជាប់ចោទចាប់តាំងពីពេលដែលសាស្ត្រាចារ្យ Campbell បានធ្វើ របាយការណ៍លើកចុងក្រោយ។

ខ) ធ្វើតេស្ត ឬបន្តធ្វើតេស្តណាមួយបន្ថែម ដែលគាត់យល់ឃើញថាជាការសមស្របដើម្បីជួយដល់ការធ្វើរោគវិនិច្ឆ័យ។

គ) ពិគ្រោះជាមួយបុគ្គលដែលមានគុណវុឌ្ឍិផ្សេងទៀត (ដូចជា វេជ្ជបណ្ឌិតជំនាញផ្នែកកាំ រស្មី) ដែលអាចជួយបកប្រែផ្ទាល់មាត់ ឬបញ្ជាក់អះអាងអំពីការសន្និដ្ឋានរបស់គាត់ស្តីពីលទ្ធផលនៃតេស្ត ឬអត្ថិភាពនៃតេស្តវេជ្ជសាស្ត្រក្នុងស្រុកដែលអ្នកជំនាញយល់ឃើញថាមានភាពចាំ បាច់សម្រាប់ការធ្វើរោគវិនិច្ឆ័យទៅលើស្ថានភាពសុខភាពនាពេលបច្ចុប្បន្នរបស់ អៀង សារី។

ឃ) ជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូង ប្រសិនបើតេស្តវេជ្ជសាស្ត្រខាងលើនេះពុំមាន អត្ថិភាពនៅឡើយនៅទីក្រុងភ្នំពេញ និង/ឬ ថាតើមានមូលដ្ឋានវេជ្ជសាស្ត្រ ឬមូលដ្ឋានជំនាញបច្ចេកវិទ្យាគ្រប់គ្រាន់ ដើម្បីធ្វើតេស្តទាំងនោះបានសមស្របដែរ ឬយ៉ាងណា។

ង) ធ្វើរបាយការណ៍មកអង្គជំនុំជម្រះសាលាដំបូងថាតើតេស្តវេជ្ជសាស្ត្រ ដែលគាត់យល់ឃើញថាចាំបាច់សម្រាប់បញ្ជាក់អះអាងអំពីការធ្វើរោគវិនិច្ឆ័យ លើស្ថានភាពសុខភាពនាពេលបច្ចុប្បន្នរបស់ អៀង សារី គួរធ្វើនៅកន្លែងណា និងក្រោមលក្ខខណ្ឌអ្វីខ្លះ។

ច) ធ្វើរបាយការណ៍មកអង្គជំនុំជម្រះសាលាដំបូងអំពីយោបល់របស់អ្នកជំនាញស្តីពីស្ថានភាពនៃសុខភាពរបស់ជនជាប់ចោទ អៀង សារី នាពេលបច្ចុប្បន្ន និងថាតើនៅពេលណាគាត់អាចចាកចេញពីមន្ទីរពេទ្យបាន។

ឆ) ជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូងអំពីការកែប្រែណាមួយ ដែលអ្នកជំនាញនឹងណែនាំនៅក្នុងការថែទាំវេជ្ជសាស្ត្រសម្រាប់ជនជាប់ចោទ អៀង សារី។